**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

**លេខ** ០០១ សណន

# សេចក្ដីណែនាំ
## ស្ដីពី
## ការជំរុញការប្រើប្រាស់ស្រោមអនាម័យឱ្យបាន១០០ភាគរយ ដើម្បីរួមគ្នាបញ្ចប់អេដស៍

យោងតាមសារាចរលេខ ២០សរ. ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៥ របស់រាជរដ្ឋាភិបាលកម្ពុជាស្ដីពីការជំរុញការប្រើប្រាស់ស្រោមអនាម័យឱ្យបាន១០០ភាគរយដើម្បីបង្ការមេរោគអេដស៍និងជំងឺអេដស៍ ក្រសួងទេសចរណ៍សូមធ្វើការណែនាំលោក លោកស្រីប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត និងលោក លោកស្រីជាម្ចាស់ ឬអ្នកគ្រប់គ្រងមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូចខាងក្រោម៖

១- បន្តចូលរួមផ្សព្វផ្សាយអំពីប្រសិទ្ធភាពនៃស្រោមអនាម័យ និងជំរុញឱ្យមានការប្រើប្រាស់ស្រោមអនាម័យឱ្យបាន១០០% នៅតាមមូលដ្ឋានសេវាកម្សាន្តនានា ដើម្បីទប់ស្កាត់ការចម្លងមេរោគអេដស៍ពីដៃគូរួមភេទ។

២- បន្តចូលរួមផ្សព្វផ្សាយអំពីហានិភ័យនៃមេរោគអេដស៍ និងលុបបំបាត់ទស្សនៈយល់ច្រឡំថា នៅកម្ពុជាគ្មានអេដស៍ទៀតទេ ព្រមទាំងជំរុញឱ្យមានការចូលរួមទាំងអស់គ្នាដើម្បីរួមគ្នាបញ្ចប់អេដស៍តាមរយៈការអនុវត្តវិធានការបង្ការការពារឱ្យបានហ្មត់ចត់ ដូចជាការប្រើប្រាស់ស្រោមអនាម័យ ១០០%ជាដើម។

៣- ជំរុញប្រជាជនគន្លឹះបម្រើការក្នុងសេវាកម្សាន្ត ដែលសង្ស័យថាមានផ្ទុកមេរោគអេដស៍ឱ្យប្រញាប់ទៅធ្វើតេស្តរកមេរោគអេដស៍ជាបន្ទាន់ ដើម្បីទទួលបានសេវាថែទាំព្យាបាលទាន់ពេលវេលា។

៤- ម្ចាស់ ឬអ្នកគ្រប់គ្រងមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍ត្រូវធានាឱ្យមានការរក្សាទុក និងផ្ដល់ជូនស្រោមអនាម័យនៅតាមមូលដ្ឋានសេវាកម្សាន្តដូចជារង្គសាល បៀរហ្គាឌិន និងមូលដ្ឋានសេវាកម្មស្នាក់នៅដូចជាសណ្ឋាគារ ផ្ទះសំណាក់ជាដើម។

៥- ស្រោមអនាម័យមិនត្រូវបានយកធ្វើជាកម្មវត្ថុនៃការដាក់បន្ទុកឡើយ លើកលែងតែការប្រើស្រោមអនាម័យក្នុងការប្រព្រឹត្តបទល្មើស។

ទទួលបានសេចក្ដីណែនាំនេះ លោក លោកស្រីប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត និងលោក លោកស្រីជាម្ចាស់ ឬអ្នកគ្រប់គ្រងមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍ត្រូវអនុវត្តសេចក្ដីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃច័ន្ទ ៩កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១២ ខែមករា ឆ្នាំ២០២៦
**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**ហួត ហាក់**

**កន្លែងទទួល៖**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរទេសចរណ៍រាជធានី ខេត្ត
- គ្រប់សមាគមឧស្សាហកម្មទេសចរណ៍
- ឯកសារ កាលប្បវត្តិ